ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:......០០២/១១....គ.ម.ក ប្រ.ក.

# ប្រកាស

## ស្តីពី

## ការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្រ

*****

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គមក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២ Fax : 855-23-885-622

Downloaded from http://www.khmerlaws.com

- បានឃើញប្រកាសលេខ ០០៤ គមក.ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ
- បានឃើញសំណើសុំការពិនិត្យ និងអនុម័ត លើវិធានប្រតិបត្តិការរក្សាទុកមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១០
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១១

## ស ម្រេ ច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវវិធានប្រតិបត្តិការរក្សាទុកមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិកនិងអ្នកចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី **០៣** ខែ **ឧសភា** ឆ្នាំ២០១១

**គាត ឈន់**

**កន្លែងទទួល ÷**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



Downloaded from http://www.khmerlaws.com

ឧបសម្ព័ន្ធប្រកាសលេខ ០០៤/១១ គ.ម.ក. ប្រ.ក.

ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១១

# វិធានប្រតិបត្តិការរក្សាទុកមូលបត្រ
# របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

*****

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- គោលបំណង**

គោលបំណងនៃវិធាននេះគឺដើម្បីកំណត់អំពីលក្ខខណ្ឌចាំបាច់នានាសម្រាប់ការរក្សាទុក និងការផ្ទេរមូលបត្រ នៅក្នុងប្រតិបត្តិកររក្សាទុកមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (សរសេរកាត់ថា **ផ.ម.ក.**) ដែលទទួលបានការអនុញ្ញាតស្របតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ ២.- និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងវិធាននេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

-**សមាជិក** សំដៅដល់ក្រុមហ៊ុនមូលបត្រ ដែលទទួលបានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា **គ.ម.ក.**) ដោយមានសិទ្ធិប្រើប្រាស់ទាំងស្រុង នូវប្រព័ន្ធរក្សាទុកមូលបត្ររបស់ **ផ.ម.ក.**។

-**អ្នកចូលរួម** សំដៅដល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រជាដើម ដែលមានសិទ្ធិប្រើប្រាស់តែមួយផ្នែកនៃសេវារបស់ប្រតិបត្តិកររក្សាទុកមូលបត្ររបស់ **ផ.ម.ក.**។

**ប្រការ ៣.- ម៉ោងអាជីវកម្ម**

ម៉ោងអាជីវកម្មស្របតាមវិធាននេះគឺចាប់ផ្តើមពីម៉ោង ៨:០០ ព្រឹក ដល់ម៉ោង ៥:០០ ល្ងាច រៀងរាល់ថ្ងៃធ្វើការ។



Downloaded from http://www.khmerlaws.com

**ប្រការ ៤.- ការកំណត់ ឬការលុបចោលនូវមូលបត្រដែលអាចរក្សាទុកបាន**

លើកលែងតែមានការកំណត់បន្ថែមផ្សេងពីនេះដោយ **គ.ម.ក.** មូលបត្រដែលអាចរក្សាទុកបាននៅប្រតិបត្តិកររក្សាទុកមូលបត្រ មានដូចខាងក្រោម :

១- មូលបត្រដែលបានចុះបញ្ជីនៅប្រតិបត្តិករទីផ្សារមូលបត្ររបស់ **ផ.ម.ក.**។

២- មូលបត្រដែលទើបបោះផ្សាយដោយក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ។

៣- មូលបត្រដែលកំពុងស្ថិតក្នុង ឬដែលនឹងចាប់ផ្តើមនីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ។

៤- មូលបត្រដែលរៀបចំចុះបញ្ជីនៅប្រតិបត្តិករទីផ្សារមូលបត្ររបស់ **ផ.ម.ក.**។

**ប្រការ ៥.- ព័ត៌មានពាក់ព័ន្ធនឹងការដាក់ផ្ញើមូលបត្រ**

ដើម្បីដាក់ផ្ញើមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់ព័ត៌មានដោយផ្ទាល់ ឬតាមរយៈភ្នាក់ងារបញ្ជិកាមូលបត្រ ដូចខាងក្រោម :

១- ប្រភេទមូលបត្រ។

២- ចំនួននៃការបោះផ្សាយ។

៣- ឈ្មោះមូលបត្រ។

៤- អក្សរកូដ។

៥- ចំនួនមូលបត្រសរុប។

៦- កាលបរិច្ឆេទបោះផ្សាយ ។

៧- កាលបរិច្ឆេទចុះបញ្ជី ។

៨- ព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងកម្មសិទ្ធិភាពលើមូលបត្រ។

## ជំពូកទី ២

## គណនីមូលបត្រ

**ប្រការ ៦.- ការបើកគណនីមូលបត្រ**

លើកលែងតែមានការកំណត់បន្ថែមផ្សេងពីនេះដោយ **គ.ម.ក.** បុគ្គលដែលអាចបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ មានដូចខាងក្រោម :

១- ក្រុមហ៊ុនមូលបត្រ។

២- ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ។



Downloaded from http://www.khmerlaws.com

បុគ្គលដូចមានក្នុងកថាខណ្ឌទី១ ខាងលើ ដែលមានបំណងបើកគណនីមូលបត្រត្រូវបំពេញបែបបទបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ។

**ប្រការ ៧.- សៀវភៅគណនីមូលបត្ររបស់សមាជិក និងអ្នកចូលរួម**

ប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវរក្សាសៀវភៅគណនីមូលបត្ររបស់សមាជិក និងអ្នកចូលរួមនីមួយៗ ដែលត្រូវមានព័ត៌មាន ព្រមទាំងសេចក្តីលម្អិតនៃប្រតិបត្តិការលើមូលបត្រដែលធ្វើដោយសមាជិក និងអ្នកចូលរួម។ លើកលែងតែមានការកំណត់បន្ថែមផ្សេងពីនេះដោយ **គ.ម.ក** ព័ត៌មានលម្អិតរួមមានដូចខាងក្រោម :

១-ឈ្មោះ និងអាសយដ្ឋានរបស់បុគ្គលស្នើបើកគណនី។

២-ប្រភេទ និងបរិមាណនៃមូលបត្រដែលរក្សាទុក និងឈ្មោះនៃក្រុមហ៊ុនបោះផ្សាយ។

៣-ហេតុផលនៃឥណទាន ឬឥណពន្ធនៃមូលបត្រដែលរក្សាទុក។

៤-ឈ្មោះ និងអាសយដ្ឋាននៃអ្នកទទួលបញ្ចាំក្នុងករណីដែលមូលបត្ររក្សាទុក ជាកម្មវត្ថុនៃការបញ្ចាំ។

៥-ក្នុងករណីមូលបត្រដែលបានដាក់ផ្ញើជាកម្មវត្ថុនៃការដាក់កំហិតលក់ត្រូវមានកំណត់សម្គាល់អំពីការណ៍នេះនិងកាលបរិច្ឆេទនៃការចេញសេចក្តីសម្រេចរបស់តុលាការអំពីការរឹបអូសឬការសម្រេចផ្សេងទៀត។

ការកាន់កាប់មូលបត្រផ្ទាល់របស់សមាជិកត្រូវកត់ត្រាដាច់ដោយឡែកពីមូលបត្រដែលជាកម្មសិទ្ធិរបស់អតិថិជន។

សៀវភៅគណនីមូលបត្ររបស់សមាជិក និងអ្នកចូលរួមត្រូវរក្សាទុកសម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ។

ក្នុងករណីដែលសមាជិក ឬក្រុមហ៊ុនបោះផ្សាយមានបំណងកែប្រែឈ្មោះ អាសយដ្ឋាន លេខចុះបញ្ជីពាណិជ្ជកម្ម ឬការបោះពុម្ពត្រាសម្គាល់ សមាជិកឬក្រុមហ៊ុនបោះផ្សាយត្រូវជូនដំណឹងដល់ប្រតិបត្តិកររក្សាទុកមូលបត្រ នូវការកែប្រែទាំងនោះ ដោយបំពេញបែបបទស្នើសុំឱ្យបានត្រឹមត្រូវ។

**ប្រការ ៨.- សៀវភៅគណនីមូលបត្ររបស់អតិថិជន**

សមាជិកដែលដាក់ផ្ញើមូលបត្ររបស់អតិថិជន នៅប្រតិបត្តិកររក្សាទុកមូលបត្រ ដោយមានការឯកភាពរបស់អតិថិជន ត្រូវរក្សាទុកនូវ "សៀវភៅគណនីអតិថិជន" ដែលមានព័ត៌មានលម្អិតដូចខាងក្រោម÷

១-ឈ្មោះ និងអាសយដ្ឋានរបស់អតិថិជន។

២-ប្រភេទ និងបរិមាណនៃមូលបត្រដែលរក្សាទុក និងឈ្មោះនៃក្រុមហ៊ុនបោះផ្សាយ។



Downloaded from http://www.khmerlaws.com

៣- ព័ត៌មាននៃប្រតិបត្តិការលើមូលបត្រ។

៤- ព័ត៌មានអំពីអតិថិជននីមួយៗ ដែលត្រូវបានរក្សាទុកនៅក្នុងសៀវភៅគណនីមូលបត្ររបស់សមាជិក និងអ្នកចូលរួម។

សៀវភៅគណនីមូលបត្ររបស់អតិថិជនត្រូវរក្សាទុកសម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ។

**ប្រការ ៩.- កាលបរិច្ឆេទសុពលភាពនៃការដាក់ផ្ញើ**

ការដាក់ផ្ញើ ការដក ឬការបង្វិលទៅវិញ និងការផ្ទេរមូលបត្ររវាងគណនី ដែលធ្វើឡើងស្របតាមវិធាននេះ ត្រូវមានសុពលភាពចាប់ពីពេលដែលព័ត៌មានពាក់ព័ន្ធ ត្រូវបានកត់ត្រាទុកនៅក្នុងសៀវភៅគណនីមូលបត្ររបស់សមាជិកនិងអ្នកចូលរួម។

**ប្រការ ១០.- ការបិទគណនីមូលបត្រ**

លើកលែងតែមានការកំណត់ផ្សេងពីនេះដោយ **គ.ម.ក.** ប្រតិបត្តិកររក្សាទុកមូលបត្រ អាចបិទគណនីមូលបត្ររបស់សមាជិក ឬអ្នកចូលរួមក្នុងករណីណាមួយដូចខាងក្រោម÷

១- សមាជិក ឬអ្នកចូលរួមស្នើសុំបិទគណនីមូលបត្រ។

២- សមាជិក ឬអ្នកចូលរួមមិនបានប្រើប្រាស់គណនីរបស់ខ្លួនក្នុងរយៈពេល ០២ (ពីរ) ឆ្នាំ។

មុននឹងបិទគណនីមូលបត្ររបស់សមាជិក ឬអ្នកចូលរួម ប្រតិបត្តិកររក្សាទុកមូលបត្រត្រូវផ្តល់ជូននូវសមតុល្យនៃការដាក់ផ្ញើនៅក្នុងគណនីមូលបត្រដែលត្រូវបិទទៅសមាជិក ឬអ្នកចូលរួមដែលពាក់ព័ន្ធ។

## ជំពូកទី ៣

## បទប្បញ្ញត្តិបន្ថែម

**ប្រការ ១១.- អ្នកតំណាងរក្សាទុកមូលបត្រ**

សមាជិកនីមួយៗ ត្រូវតែងតាំង និងចុះឈ្មោះអ្នកតំណាងរក្សាទុកមូលបត្ររបស់ខ្លួនយ៉ាងហោចណាស់ចំនួន ០១ (មួយ) រូប ដែលត្រូវទទួលការបណ្តុះបណ្តាលពី **ផ.ម.ក.** និងដែលត្រូវមានសិទ្ធិធ្វើប្រតិបត្តិការរក្សាទុកមូលបត្រឱ្យសមាជិកនោះ។

អ្នកតំណាងរក្សាទុកមូលបត្ររបស់សមាជិកនេះ អាចជាអ្នកតំណាងទូទាត់ដែលត្រូវបានតែងតាំងដោយសមាជិកស្របតាមវិធានប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្រ របស់ **ផ.ម.ក.**។

**ប្រការ ១២.- ការជូនដំណឹងអំពីសមតុល្យ**

ប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវជូនដំណឹងដល់សមាជិក និងអ្នកចូលរួមអំពីសមតុល្យនៃគណនីមូលបត្រ ដែលបានដាក់ផ្ញើនៅរៀងរាល់ចុងខែនីមួយៗ។ ការជូនដំណឹងអំពីសមតុល្យគណនីនេះអាចត្រូវ



Downloaded from http://www.khmerlaws.com

បានជំនួសដោយការដាក់ជូននូវសេចក្តីចម្លងនៃសៀវភៅគណនីមូលបត្ររបស់សមាជិក ឬរបស់អ្នកចូលរួម។

**ប្រការ ១៣.- កម្រៃសេវា**

សមាជិក និងក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ ត្រូវបង់ប្រាក់កម្រៃសេវារក្សាទុកមូលបត្រ ប្រាក់កម្រៃផ្ទេររវាងគណនីមូលបត្រនិងប្រាក់កម្រៃសេវាផ្សេងទៀតសម្រាប់សេវាដែលបានទទួលស្របតាមប្រការនេះ។

សមាជិក និងក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ ត្រូវបង់ប្រាក់កម្រៃសេវាជូន **ផ.ម.ក.** ដូចខាងក្រោម ÷

១- ប្រាក់កម្រៃសេវារក្សាទុកមូលបត្រ : ជាកម្រៃសម្រាប់ការដាក់ផ្ញើមូលបត្រដែលស្ថិតក្នុងនីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ Initial Public Offerings (IPO)។ ប្រាក់កម្រៃសេវារក្សាទុកមូលបត្រប្រចាំខែ ត្រូវបង់នៅថ្ងៃទី ១០ នៃខែ បន្ទាប់ពីខែដែលប្រាក់កម្រៃនោះបានកើតឡើង ហើយមូលបត្រដែលបានដាក់ផ្ញើ ត្រូវបានដកទៅវិញដោយសារមូលហេតុនៃការបិទគណនីនៅកាលបរិច្ឆេទបិទគណនីតាមលក្ខខណ្ឌដូចខាងក្រោម :

ក- អត្រា២០ (ម្ភៃ) រៀលលើមូលដ្ឋាននៃទឹកប្រាក់ ១០.០០០.០០០ (ដប់លាន) រៀល។ ក្នុងករណីនេះកម្រៃសេវា ត្រូវកំណត់យកលើមូលដ្ឋានសមតុល្យប្រចាំថ្ងៃ ដែលបង្ហាញជូននៅក្នុងសៀវភៅគណនីមូលបត្រ។

ខ- អ្នកត្រូវបង់ប្រាក់ជាបុគ្គលដែលទទួលការអនុញ្ញាតឱ្យដាក់ផ្ញើមូលបត្រ។

២- កម្រៃសេវាផ្ទេរមូលបត្ររវាងគណនី (Book Entry Fee) :

ក- អត្រាប្រាក់កម្រៃនៃការផ្ទេរមូលបត្ររវាងគណនី ត្រូវគណនាលើមូលដ្ឋាន ទឹកប្រាក់នៃការជួញដូរ ដែលបានទូទាត់ តាមអត្រា ១០/១០.០០០ (ដប់ភាគមួយម៉ឺន) ចំពោះមូលបត្រកម្មសិទ្ធិហើយទឹកប្រាក់កម្រៃសេវាត្រូវកាត់យកមួយខ្ទង់ក្រោយក្បៀស។

ខ- អ្នកត្រូវបង់ប្រាក់ជាក្រុមហ៊ុនមូលបត្រជាសមាជិក។

គ- ពេលវេលាបង់ប្រាក់នៅម៉ោង ៨:៣០ ព្រឹក នៅកាលបរិច្ឆេទទូទាត់។

៣- កម្រៃប្រតិបត្តិការផ្សេងៗ :

ក- ប្រាក់កម្រៃនៃការផ្ទេរមូលបត្រដែលមិនត្រូវបានជួញដូរ គឺ ១៥ (ដប់ប្រាំ) រៀល លើមូលដ្ឋាននៃទឹកប្រាក់ ១០.០០០.០០០ (ដប់លាន) រៀល ។ សមាជិក និងក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ ត្រូវបង់ប្រាក់កម្រៃនេះជូនប្រតិបត្តិកររក្សាទុកមូលបត្រនៃ **ផ.ម.ក.** នៅពេលស្នើសុំផ្ទេរមូលបត្រ ។

ខ- កម្រៃនៃការដកមូលបត្រ គឺ ២០ (ម្ភៃ) រៀល លើមូលដ្ឋាននៃទឹកប្រាក់ ១០.០០០.០០០ (ដប់លាន) រៀល ។ សមាជិក និងក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ ត្រូវបង់ប្រាក់កម្រៃនេះជូនប្រតិបត្តិកររក្សាទុកមូលបត្រនៃ **ផ.ម.ក.** នៅពេលស្នើសុំផ្ទេរមូលបត្រ ។

*****



Downloaded from http://www.khmerlaws.com